**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# លិខិតអំពាវនាវ

ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣០ ទិវាពលកម្មអន្តរជាតិ ១ ឧសភា និងដើម្បីបង្កើតបរិយាកាសសប្បាយរីករាយ ជូនបងប្អូនកម្មករ-កម្មការិនី ដែលកំពុងបម្រើការងារក្នុងវិស័យឧស្សាហកម្ម ផ្នែកវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមសហការ ជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ស្ថានីយទូរទស្សន៍PNN អង្គការវិជ្ជាជីវៈ និងដៃគូពាក់ព័ន្ធនានា នឹងរៀបចំ**កម្មវិធីសម្រស់ឯកវាយនភណ្ឌឆ្នាំ២០១៦** នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦។

កម្មវិធីនេះប្រព្រឹត្តទៅដូចខាងក្រោម៖

១.វគ្គជម្រុះលើកទី១ នឹងប្រព្រឹត្តទៅនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៦ នៅ៖

- មណ្ឌលរាជធានីភ្នំពេញ៖ បេក្ខជន១០រូប បេក្ខនារី១០រូប លើបេក្ខជនសរុប ដែលបានដាក់ពាក្យនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- មណ្ឌលខេត្តព្រះសីហនុ៖ បេក្ខជន០៥រូប បេក្ខនារី០៥រូប លើបេក្ខជនសរុប ដែលបានដាក់ពាក្យនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ
- មណ្ឌលខេត្តស្វាយរៀង៖ បេក្ខជន០៥រូប បេក្ខនារី០៥រូប លើបេក្ខជនសរុប ដែលបានដាក់ពាក្យនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀង

២.កម្មវិធីប្រឡងផ្តាច់ព្រ័ត្រ៖ ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង ១៧:០០នាទី នៅស្ថានីយទូរទស្សន៍PNN (ផ្សាយផ្ទាល់)។

ដើម្បីលើកទឹកចិត្តដល់បងប្អូនកម្មករ-កម្មការិនី ជាបេក្ខជនរបស់យើង និងដើម្បីឱ្យកម្មវិធីនេះមានភាពអធិកអធម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមអំពាវនាវដល់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ជាពិសេសប្រធានរោងចក្រ សហគ្រាស មេត្តាចូលរួមទស្សនា និងគាំទ្រជាវិភាគទាន ឬសម្ភារដល់បេក្ខជន បេក្ខនារី និងកម្មវិធីទាំងមូលដោយមេត្រីភាព។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមថ្លែងអំណរគុណទុកជាមុន និងប្រសិទ្ធពរបវរមហាប្រសើរជូនដល់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា សូមមានសុខភាពល្អ និងប្រកបដោយពុទ្ធពរទាំង៤ប្រការកុំបីឃ្លៀងឃ្លាតឡើយ។ ៧៤

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៦

រដ្ឋមន្ត្រី

**អ៊ិត សំហេង**


លេខទូរសព្ទទំនាក់ទំនង៖

លោក ហ៊ិន វណ្ណា

០៩៧ ៩០៩ ៧៧៧៧